Australian Government
Medicare Australia

Australian organ donor register

# បញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គអូស្ត្រាលី (Australian Organ Donor Register)

## តើបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គជាអ្វី?

បញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គអូស្ត្រាលី (បញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ) អនុញ្ញាតឲ្យមនុស្សទាំងឡាយចុះកំណត់ត្រាសេចក្តីសំរេចរបស់គេ អំពីការធ្វើជាអ្នកធ្វើអំណោយសរីរាង្គ និងជាលិកាសំរាប់ផ្សាំ ក្រោយពីខ្លួនបានបាត់បង់ជីវិត។

បុគ្គលិកពេទ្យដែលមានការអនុញ្ញាតអាចបើកមើលបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ 24 ម៉ោងក្នុងមួយថ្ងៃ។

ការនេះគឺដើម្បីឲ្យបានប្រាកដថា ក្នុងករណីនៃការបាត់បង់ជីវិត សេចក្តីសំរេចរបស់បុគ្គលដើម្បីធ្វើអំណោយត្រូវបានគេកត់ត្រាទុក ហើយអាចបើកមើលបាន។

ការកត់ត្រាសេចក្តីសំរេចរបស់លោកអ្នកនៅលើបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយគឺជាការស្ម័គ្រចិត្ត ហើយលោកអ្នកមានជម្រើសពេញលេញអំពីសរីរាង្គ និងជាលិកាមួយណាដែលលោកអ្នកត្រៀមខ្លួនក្នុងការផ្តល់ជាអំណោយ។ ការផ្តល់អំណោយអាចជាប់ពាក់ព័ន្ធនឹង៖

- សរីរាង្គ – ដែលមានរួមទាំងតម្រងនោម បេះដូង សួត ថ្លើម និងលំពែង
- ជាលិកា – ដែលមានរួមទាំងសន្ទះបិទបើកដំណើរឈាមនៃបេះដូង ជាលិកាឆ្អឹង ជាលិកាស្បែក និងជាលិកាភ្នែក។

បើលោកអ្នកមិនចង់ក្លាយជាអ្នកធ្វើអំណោយសរីរាង្គ ឬជាលិកាទេ លោកអ្នកក៏អាចចុះកំណត់ត្រាសេចក្តីសំរេចរបស់លោកអ្នកក្នុងការមិនធ្វើអំណោយនៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយផងដែរ។

## ហេតុអ្វីបានជាខ្ញុំគួរគិតដល់ការធ្វើអំណោយសរីរាង្គ និងជាលិកា?

ចំពោះជនដែលមានជម្ងឺធ្ងន់ធ្ងរ ឬជម្ងឺយាយីដល់ជីវិត ការផ្សាំសរីរាង្គ ឬជាលិកាអាចមានន័យថាជាឱកាសដើម្បីរស់រានមានជីវិតម្តងទៀត។ ប្រជាពលរដ្ឋអូស្ត្រាលីជាង 30 000 នាក់ បានទទួលការផ្សាំសរីរាង្គ និងជាលិកានៅរយៈពេល 60 ឆ្នាំកន្លងមកនេះ។ ឥឡូវនេះ អត្រាកាន់តែប្រសើរឡើងនៃការរស់រានមានជីវិតមានន័យថា អ្នកទទួលសរីរាង្គ ឬជាលិកាភាគច្រើនអាចទទួលបានជីវិតមួយដែលប្រកបដោយគុណភាពរឹតតែប្រសើរឡើង។ ដោយជ្រើសរើសការកត់ត្រាទុកនូវសេចក្តីប្រាថ្នារបស់លោកអ្នកនៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ លោកអ្នកអាចជួយមនុស្សរហូតដល់ 10 នាក់។

## តើខ្ញុំមានសិទ្ធិចុះឈ្មោះឬទេ?

អ្នកណាក៏ដោយឲ្យតែមានអាយុ 16 ឆ្នាំឡើងទៅ ហើយរស់នៅក្នុងប្រទេសអូស្ត្រាលី អាចចុះកំណត់ត្រាការយល់ព្រមរបស់ខ្លួននៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយបាន។

ជនរាល់រូបអាចធ្វើអំណោយសរីរាង្គ និងជាលិកាបាន។ គ្មានការរឹតត្បិតលើអាយុចំពោះការធ្វើអំណោយសរីរាង្គ និងជាលិកាខ្លះនោះទេ។ ទោះជានឹងមានការពិចារណាអំពីអាយុ និងប្រវត្តិជំងឺរបស់លោកអ្នកក្តី ក៏លោកអ្នកមិនគួរសន្មត់ថាលោកអ្នកមានវ័យក្មេងពេក ចាស់ពេក ឬក៏គ្មានសុខភាពល្អគ្រប់គ្រាន់នោះឡើយ។

## តើខ្ញុំអាចចុះឈ្មោះដោយរបៀបណា?

លោកអ្នកអាចចុះឈ្មោះតាមរយៈ៖

- ផ្ទាល់ខ្លួន នៅឯការិយាល័យមេឌីឃែរណាមួយ
- ទូរស័ព្ទទៅលេខ **1800 777 203****
- អ៊ីនធើណិត—**www.medicareaustralia.gov.au**

បើលោកអ្នកមិនចង់ក្លាយទៅជាអ្នកធ្វើអំណោយសរីរាង្គ ឬជាលិកាទេ លោកអ្នកអាចកត់ត្រាសេចក្ដីសំរេចរបស់លោកអ្នកក្នុងការមិនផ្ដល់អំណោយនេះ នៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ តាមលក្ខណៈដូចគ្នានេះដែរ។

## តើខ្ញុំអាចផ្លាស់ប្ដូរព័ត៌មានដែលកត់ត្រាក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយរបៀបណា?

លោកអ្នកអាចផ្លាស់ប្ដូរព័ត៌មានណាមួយរបស់លោកអ្នក ដែលបានកត់ត្រានៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ ដោយមានរួមទាំងសេចក្ដីសំរេចធ្វើអំណោយ តាមរយៈការបំពេញពាក្យសុំផ្លាស់ប្ដូរព័ត៌មានដែលអាចយកបានពីការិយាល័យមេឌីឃែរណាមួយ ឬក៏តាមអ៊ីនធើណិត **www.medicareaustralia.gov.au**

## តើហេតុអ្វីបានជាខ្ញុំត្រូវផ្ដល់លេខមេឌីឃែររបស់ខ្ញុំនៅក្នុងបញ្ជីចុះឈ្មោះនោះ?

នៅក្នុងពេលដែលទង្វើនេះមិនមែនជាតម្រូវការខានមិនបានក្ដី ក៏ការផ្ដល់លេខមេឌីឃែររបស់លោកអ្នកនឹងជួយយើងខ្ញុំក្នុងការរក្សាព័ត៌មាននៃអាសយដ្ឋានរបស់លោកអ្នក។ ការកង្វះនូវព័ត៌មាននៃអាសយដ្ឋានបច្ចុប្បន្នអាចបណ្ដាលឲ្យបាត់បង់ឱកាសមួយក្នុងការជួយសង្គ្រោះជីវិត។

## តើខ្ញុំគួរពិភាក្សាពីសេចក្ដីសំរេចរបស់ខ្ញុំ អំពីការធ្វើអំណោយជាមួយគ្រួសារ គូកំណាន់ ឬមិត្តជិតស្និទ្ធរបស់ខ្ញុំឬ?

ជាការសំខាន់ដែលលោកអ្នកពិភាក្សាអំពីការសំរេចក្នុងការធ្វើអំណោយសរីរាង្គរបស់លោកអ្នក ជាមួយគ្រួសារ គូកំណាន់ ឬមិត្តជិតស្និទ្ធរបស់អ្នក។ អ្នកទាំងនោះនឹងទៅជាផ្នែកសំខាន់មួយនៃដំណើរការធ្វើអំណោយ ហេតុដូច្នេះហើយលោកអ្នកត្រូវធ្វើឲ្យច្បាស់ថាអ្នកទាំងនោះដឹងអំពីសេចក្ដីសំរេចរបស់លោកអ្នកក្នុងការចុះឈ្មោះធ្វើអំណោយ។

សមាជិកគ្រួសារ ដៃគូ ឬមិត្តភក្ដិជិតស្និទ្ធអាចនឹងត្រូវបានសុំឲ្យបញ្ជាក់ថា លោកអ្នកមិនបានផ្លាស់ប្ដូរចិត្តទេចាប់តាំងពីពេលដែលលោកអ្នកបានចុះឈ្មោះពីសេចក្ដីសំរេចរបស់លោកអ្នកមក។ នៅពេលដែលលោកអ្នកបានចុះឈ្មោះអនុញ្ញាតធ្វើអំណោយសរីរាង្គ និង/ឬ ជាលិកា គេអាចនឹងសួរអ្នកទាំងនោះនូវសំណួរនានាអំពីប្រវត្តិជំងឺរបស់លោកអ្នក ដើម្បីកំណត់ថាតើសរីរាង្គ និង/ឬជាលិកាណាមួយដែលសមរម្យសំរាប់ការផ្សាំ។

បើសមាជិកគ្រួសារចំនួនកាន់តែច្រើនបានដឹង អំពីការសំរេចរបស់លោកអ្នកក្នុងការធ្វើអំណោយសរីរាង្គ និងជាលិកា អ្នកទាំងនោះនឹងរឹតតែងាយស្រួលក្នុងការធ្វើឲ្យច្បាស់ថានឹងមានការគោរព និងការអនុវត្តតាមសេចក្ដីសំរេចរបស់លោកអ្នក។

## តើនៅពេលណាដែលអំណោយសរីរាង្គ និងជាលិកានឹងអាចកើតមានឡើង?

នៅក្នុងករណីភាគច្រើន ជនណាមួយអាចធ្វើអំណោយសរីរាង្គតែនៅក្នុងពេលដែលមានការប្រកាសថាខួរក្បាលរបស់ជននោះស្ថិតនៅក្នុងបន្ទប់ថែទាំអ្នកជម្ងឺធ្ងន់នៅមន្ទីរពេទ្យបានស្លាប់ទៅហើយ។ ខួរក្បាលស្លាប់នៅពេលដែលឈាមឈប់រត់ទៅកាន់ខួរក្បាល ហើយខួរក្បាលឈប់បំពេញមុខងារ និងអស់ជីវិតទៅហើយ ដោយគ្មានលទ្ធភាពជាសះស្បើយឡើងវិញបានទេ។ វេជ្ជបណ្ឌិតឯករាជ្យជាន់ខ្ពស់ពីរនាក់ ហើយមានលក្ខណៈសម្បត្តិសមរម្យ ត្រូវធ្វើតេស្តមួយចំនួនដើម្បីឲ្យដឹងថាខួរក្បាលបានស្លាប់ទៅហើយ។

មានមនុស្សតិចជាង 1 ភាគរយដែលស្លាប់នៅក្នុងមន្ទីរពេទ្យរាល់ឆ្នាំ ស្លាប់តាមរបៀបនេះ ហេតុនេះអ្នកទាំងនោះអាចធ្វើអំណោយសរីរាង្គរបស់ខ្លួន។

ជួនកាល មានមនុស្សខ្លះមានការបារម្ភ ឬភាន់ច្រឡំអំពីភាពខុសគ្នារវាងខួរក្បាលស្លាប់ និងភាពភ្លឹកមិនដឹងខ្លួន។ ខួរក្បាលស្លាប់ មានលក្ខណៈខុសគ្នាទាំងស្រុងទៅនឹងភាពភ្លឹកមិនដឹងខ្លួន។ អ្នកជំងឺនៅក្នុងភាពភ្លឹកគឺសន្លប់មិនដឹងខ្លួន ដោយសារខួរក្បាលរបស់អ្នកនោះមានរបួសដោយសារអ្វីមួយ តែខួរក្បាលនៅតែដើរ ហើយអាចជាសះឡើងវិញ។ ការធ្វើតេស្តលើអ្នកជំងឺអាចបង្ហាញច្បាស់ពីលក្ខណៈខុសគ្នារវាងខួរក្បាលស្លាប់ និងភាពភ្លឹក។

មនុស្សកាន់តែច្រើនឡើងមានឱកាសធ្វើអំណោយជាលិកាសំរាប់ផ្សាំ ដូចជាជាលិកាភ្នែក សន្ទះបិទបើកបេះដូង ជាលិកាឆ្អឹង និងជាលិកាស្បែក។ នេះគឺដោយសារថាដើម្បីឲ្យការផ្សាំមានជោគជ័យ អំណោយជាលិកាមិនត្រូវការកាលៈទេសៈដូចគ្នានឹងអំណោយសរីរាង្គឡើយ។

## តើគេកាត់យកសរីរាង្គ និងជាលិកាចេញតាមរបៀបណា?

ការកាត់យកសរីរាង្គ និងជាលិកាចេញ មិនខុសពីការវះកាត់ឯទៀតៗទេ ហើយត្រូវបានធ្វើឡើងដោយបណ្ដាអ្នកមានជំនាញថ្វីដៃដ៏ពូកែ។ ការប៉ះពាល់ខ្លួនប្រាណរបស់អ្នកធ្វើអំណោយ ត្រូវបានធ្វើឡើងប្រកបដោយភាពគោរព និងភាពថ្លៃថ្នូរ។ អំណោយសរីរាង្គ និងជាលិកាមិនធ្វើឲ្យកែប្រែដល់រូបរាងកាយសាកសព ព្រមទាំងមិនប៉ះពាល់ដល់ការរៀបចំធ្វើពិធីបុណ្យឈាបនកិច្ចឡើយ។

## បញ្ជីផ្ទៀងផ្ទាត់ / បញ្ជីឆែកមើលដោយសង្ខេប

- កត់ត្រាសេចក្តីសំរេចធ្វើអំណោយសរីរាង្គ និង/ឬជាលិការបស់លោកអ្នកនៅក្នុងបញ្ជីចុះឈ្មោះ។
- និយាយទៅកាន់គ្រួសារលោកអ្នក ដើម្បីធ្វើឲ្យច្បាស់ថាអ្នកទាំងនោះដឹងអំពីសេចក្តីប្រាថ្នារបស់លោកអ្នក។

## ចំពោះព័ត៌មានបន្ថែមអំពីបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយ

| | |
|---|---|
| វិបសាយ | **www.medicareaustralia.gov.au** |
| អ៊ីមែល | **aodr@medicareaustralia.gov.au** |
| ទូរស័ព្ទ | **1800 777 203**** |
| TTY | **1800 552 152**** (ចំពោះអ្នកមានពិការភាពខាងស្តាប់ និងនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសា) |

*គិតថ្លៃទូរស័ព្ទ។

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

## ចំពោះព័ត៌មានបន្ថែមទៀតអំពីអំណោយសរីរាង្គ និងជាលិកា

**New South Wales**

Level 6, 4 Belgrave Street

Kogarah NSW 2217

ទូរស័ព្ទ **02 8566 1700**

**Australian Capital Territory**

Canberra Hospital

Yamba Drive, Garran ACT 2605

ទូរស័ព្ទ **02 6244 3071**

**South Australia**

Level 6, 45 Grenfell Street

Adelaide SA 5000

ទូរស័ព្ទ **08 8207 7117**

**Northern Territory**

1st floor, Royal Darwin Hospital

Rocklands Drive, Tiwi NT 0810

ទូរស័ព្ទ **08 8922 8786**

**Victoria**

538 Swanson Street

Carlton VIC 3053

ទូរស័ព្ទ **03 9349 4762**

**Queensland**

Level 4, Building 1

Princess Alexandra Hospital

Ipswich Road, Woolloongabba QLD 4102

ទូរស័ព្ទ **07 3240 2350**

**Western Australia**

6th floor, Albert Facey House

469 Wellington Street, Perth WA 6000

ទូរស័ព្ទ **08 9222 0222**

**Tasmania**

Level 3, Hobart Corporate Centre

85 Macquarie Street, Hobart TAS 7000

ទូរស័ព្ទ **03 6270 2209**

**Australian Organ and Tissue Authority**

Level 5, 51 Allara Street

Canberra City ACT 2600

ទូរស័ព្ទ **02 6198 9800**

1577_12d.04.11.09